# បច្ឆិមវាចា

*វាចាចុងក្រោយបំផុតរបស់ព្រះពុទ្ធ*

| | |
|---|---|
| ហន្ទៈ អ្នកទាំងឡាយ | គ្រប់រូបកាយមកអាយ៉ា |
| តថាគតនឹងមតា[1] | ចាកចោលបាតឡូវហើយ ។ |
| សង្ខារមិនទៀងទេ | ចូរគ្នាន់គ្នេរកុំកន្តើយ |
| វាអន់អស់ទៅហើយ | មិនទៅឡើយដូចធម្មតា ។ |
| ប្រែប្រួលម្តងបន្តិច | ជាប់ជានិច្ចរាល់វេលា |
| យើងគេទាំងអស់គ្នា | គ្មាននរណាគេចផុតបាន ។ |
| អនិច្ចំ និង ទុក្ខា | អនត្តាមានគ្រប់ប្រាណ |
| អ្នកក្រ ឬ អ្នកមាន | ល្ងង់ ឬ ចេះមានស្មើគ្នា ។ |
| សូម្បីទ្រព្យសម្បត្តិ | វត្ថុអ្វីផងនានា |
| កើតឡើងក្នុងលោកា | នៅនាក្រោមច្បាប់ត្រៃលក្ខណ៍ ។ |
| ចូរនាំគ្នាសិក្សា | ពិចារណាឲ្យយល់ជាក់ |
| ច្បាស់ច្បាប់ព្រះត្រៃលក្ខណ៍ | ហើយពួកអ្នកកុំប្រកាន់ ។ |
| ឈប់យល់ថាខ្លួនអញ | ត្រូវយល់ថាជាបញ្ចក្ខន្ធ |
| គ្មានអ្វីគួរក្អួចកាន់ | ថាជាអញយើងគេឡើយ ។ |
| ប្រកាន់បានតែទុក្ខ | ឈប់ប្រកាន់បានសុខស្បើយ |
| ឈប់ទូលរែកពុនហើយ | ដាក់វាចុះអស់ធ្ងន់ទៀត ។ |
| ហេតុនេះអ្នកទាំងឡាយ | គ្រប់រូបកាយកុំប្រមាទ |
| សតិខំសង្វាត | លះអំពើទុច្ចរិត ។ |
| ដោយកាយ និង វាចា | បីនេះណាព្រមទាំងចិត្ត |
| មិច្ឆាទិដ្ឋិពិត | ត្រូវតែលះបង់ចោលផង ។ |

[1] មតា ត្រឹមត្រូវជាង មរណាមិនត្រូវទេ ប៉ុន្តែ គេចេះតែប្រើទៅ ។

| | |
|---|---|
| ហើយនាំគ្នាចំរើន | សុចរិតឲ្យហ្មត់ហ្មង |
| សម្មាទិដ្ឋិផង | ត្រូវចំរើនឲ្យច្រើនណា៎ ! ។ |
| សតិកុំគ្រេកអរ | ក្នុងអ្វីគួរគាប់ប្រាថ្នា |
| កុំក្រោធខឹងទោសា | ក្នុងអ្វីគួរតែប្រទូស្ត ។ |
| កុំមានក្តីវង្វេង | ក្នុងអ្វីគួរវង្វេងនោះ |
| សតិតាំងចំពោះ | រារាំងទប់ចិត្តឲ្យបាន ។ |
| កុំឲ្យចិត្តស្រវឹង | ក្នុងអារម្មណ៍ពាលសាមាន្យ |
| ប្រព្រឹត្តដូចតិរច្ឆាន | មិនសមឋានជាមនុស្សឡើយ ។ |
| អ្នកដែលប្រមាទនោះ | សូម្បីរស់ដូចស្លាប់ហើយ |
| ព្រោះគ្មានក្តីល្អឡើយ | កើតឡើងដោយក្តីប្រមាទ ។ |
| អ្នកដែលធ្វើល្អវិញ | ចិត្តគេមិញជ្រះថ្លាស្អាត |
| ព្រោះគេមិនប្រមាទ | សូម្បីស្លាប់ទុកដូចរស់ ។ |
| ពាក្យនេះន័យជ្រៅណាស់ | រៀនឲ្យច្បាស់សព្វទាំងអស់ |
| សង្ខេបត្រឹមណឹងចុះ | ចប់ចរចូលនិព្វានហោង ៕ |

**ចាកសេចក្តីមិនប្រមាទ ២០០១**

| | |
|---|---|
| **យោ សហស្សំ សហស្សេន** | **សង្គាមេ មានុសេ ជិនេ** |
| **ឯកញ្ច ជេយ្យមត្តានំ** | **សវេ សង្គាមជុត្តមោ ។** |
| ឈ្នះមនុស្សមួយលានក្នុងសង្គ្រាម | ពុំទាន់បាននាមថាប្រសើរ |
| ឈ្នះខ្លួនតែម្នាក់ឯងទេតើ | ទើបបានប្រសើរ ក្នុងសង្គ្រាម ។ |

**កុំចង់ឈ្នះគេ ត្រូវចង់ឈ្នះខ្លួនឯងផង**